អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះតុលាការកំពូល សម្រេចផ្តន្ទាទោស កាំង ហ្កេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារអស់មួយជីវិត

ថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសម្រេចផ្តន្ទាទោស កាំង ហ្កេកអ៊ាវ ហៅ ឌុច ដាក់ពន្ធនាគារអស់មួយជីវិត ជាទោសអតិបរមា ដែលមានចែងក្នុងច្បាប់ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។

ដោយបានទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធចោលការផ្តន្ទាទោសដាក់ពន្ធនាគារ ៣៥ឆ្នាំ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ហើយមតិភាគច្រើនលើសលប់របស់អង្គជំនុំជម្រះតុលាការកំពូល ក៏បានបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសងសំណងចំពោះការរំលោភលើសិទ្ធិរបស់ កាំង ហ្កេកអ៊ាវ ដោយសារការឃុំខ្លួនខុសនីតិវិធីច្បាប់ ដោយតុលាការយោធាកម្ពុជាចាប់តាំងពីថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧។ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធចោលបណ្តឹងសាទុក្ខរបស់ កាំង ហ្កេកអ៊ាវ ដែលបានលើកឡើងថា ខ្លួនមិនស្ថិតនៅក្នុងយុត្តាធិការលើរូបបុគ្គលរបស់តុលាការទេ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ចំពោះបញ្ហា ថាតើជនជាប់ចោទគឺជាមេដឹកនាំជាន់ខ្ពស់មួយរូប ឬជាជនមួយរូបក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដែរ ឬយ៉ាងណានោះ គឺជាសេចក្តីសម្រេចផ្តាច់មុខផ្នែកគោលការណ៍ណែនាំ របស់សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ដែលជាអ្នកទទួលខុសត្រូវ។

អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់មិនសមហេតុផលចំពោះស្ថានសម្រាលទោស និងមិនបានផ្តល់ទម្ងន់ឲ្យបានគ្រប់គ្រាន់ចំពោះស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងស្ថានទម្ងន់ទោស នៅក្នុង

ការសម្រេចផ្តន្ទាទោសនោះទេ។ ពាក់ព័ន្ធនឹងកត្តាស្ថានទម្ងន់ទោស អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ជនជាប់ចោទមានតួនាទីជាមេដឹកនាំធំជាងគេនៅមន្ទីរ សស២១ ហើយជនជាប់ចោទបានបំពានតួនាទីរបស់ខ្លួន ដោយបានបង្ហាត់បង្រៀន បញ្ជា និងគ្រប់គ្រងទៅលើបុគ្គលិកក្នុងការធ្វើទារុណកម្មជាប្រព័ន្ធ និងការសម្លាប់អ្នកទោសដែលត្រូវបានចាត់ទុកថាជាសត្រូវរបស់របបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការបង្ហាញ "ការខិតខំប្រឹងប្រែងបំពេញភារកិច្ចដើម្បីធ្វើឲ្យមន្ទីរ ស២១ ដំណើរការទៅបានយ៉ាងរលូន" ដែលជា "ទីកន្លែងសម្លាប់មនុស្សដ៏ធំដោយមានការរៀបចំ"។

អង្គជំនុំជម្រះបានកត់សម្គាល់ថា ចំនួនមនុស្សស្លាប់ដ៏ច្រើនដែល កាំង ហ្កេកអ៊ាវ ជាអ្នកទទួលខុសត្រូវនោះ (ជាអប្បបរមា ១២.២៧២ នាក់) ព្រមទាំងរយៈពេលដ៏វែងនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត (ជាងបីឆ្នាំ) គឺពិតជាធ្វើឲ្យសំណុំរឿងនេះ ជាសំណុំរឿងមួយដែលមានលក្ខណៈធ្ងន់ធ្ងរជាងគេបំផុត នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ អង្គជំនុំជម្រះក៏បានយល់ឃើញផងដែរថា ការពិតដែលថាជនជាប់ចោទមិនមែនជាជនកំពូលនៃខ្សែបណ្តាញបញ្ជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចធ្វើជាយុត្តិកម្មក្នុងការកាត់បន្ថយទោសនោះបានទេ ហើយថា មិនមានវិធានណាមួយ ដែលចែងអំពីកម្រិតនៃការផ្តន្ទាទោសខ្ពស់បំផុតចំពោះចារី ដែលត្រូវបានចាត់ទុកជាជនកំពូលនៃខ្សែបណ្តាញបញ្ជានោះទេ។

សំឡេងភាគច្រើនលើសលប់ (ជំទាស់ដោយចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe) យល់ឃើញទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយយុត្តិសាស្ត្រពាក់ព័ន្ធ របស់តុលាការអន្តរជាតិ ឲ្យមានខ្លឹមសារថា ការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទ គប្បីត្រូវទទួលបានការទូទាត់ពី អ.វ.ត.ក ទោះបីជាមិនមែនជាការរំលោភបំពានរបស់ អ.វ.ត.ក និងទោះបីជាមិនមានការរំលោភលើកិច្ចដំណើរការនីតិវិធីក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងគួរតែបានបដិសេធសំណើសុំសំណង របស់ជនជាប់ចោទរួចទៅហើយ ដោយសារតែការពុំមានស្ថានភាពទាំងពីរនេះ។

ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe យល់ឃើញថា ការផ្តល់សំណងគឺជាការទទួលខុសត្រូវរបស់ អ.វ.ត.ក ហើយថា ការផ្តល់ឲ្យ កាំង ហ្កេកអ៊ាវ នូវសំណងដោយការកាត់បន្ថយទោសពីការដាក់ពន្ធនាគារអស់មួយជីវិត មកនៅត្រឹមការដាក់ពន្ធនាគារមានកំណត់រយៈពេលត្រឹម ៣០ឆ្នាំ គឺជាការសមស្រប។

អង្គជំនុំជម្រះតុលាការកំពូលក៏បានយល់ព្រមតាមបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមួយផ្នែក ដែលបានស្នើសុំឲ្យសម្រេចអំពីពិរុទ្ធភាពពីបទល្មើសច្រើនអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងសំអាងហេតុរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយបានដាក់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ ទៅក្នុងឧក្រិដ្ឋកម្ម នៃការធ្វើទុក្ខបុកម្នេញ ជំនួសឲ្យការសម្រេច

អំពីពិរុទ្ធភាពរបស់ កាំង ហ្គេកអ៊ាវ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ ដែលតុលាការបានរកឃើញថា គាត់ជាអ្នកទទួលខុសត្រូវ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់ការសម្រេចអំពីពិរុទ្ធភាព ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ និងបានបញ្ចូលការសម្រេចអំពីពិរុទ្ធភាពបន្ថែមទៀតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ព្រមទាំងអំពើអមនុស្សធម៌ផ្សេងទៀត។

អង្គជំនុំជម្រះតុលាការកំពូលក៏បានយល់ព្រមតាមបណ្តឹងសាទុក្ខ ដែលធ្វើឡើងដោយអ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ នាក់ ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលនៅក្នុងសាលក្រម។ ម្ចាស់បណ្តឹងសាទុក្ខជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះបានបង្ហាញភស្តុតាងបន្ថែមនៅក្នុងពាក្យសុំរបស់ខ្លួននៅពេលប្តឹងសាទុក្ខ ហេតុដូច្នេះហើយពួកគាត់ត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១។

អង្គជំនុំជម្រះតុលាការកំពូលក៏បានធ្វើសេចក្តីសម្រេចលើបណ្តឹងសាទុក្ខ ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើរបស់ពួកគាត់សុំសំណងសមូហភាព និងសំណងផ្លូវចិត្តផងដែរ។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចតម្កល់សេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចចងក្រង និងចុះផ្សាយនៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក នូវរាល់សេចក្តីថ្លែងសុំអភ័យទោស និងការទទួលស្គាល់ការទទួលខុសត្រូវដែលបានធ្វើឡើងដោយ កាំង ហ្គេកអ៊ាវ នៅក្នុងអំឡុងពេលដំណើរការសវនាការ រួមទាំងនៅដំណាក់កាលប្តឹងសាទុក្ខផងដែរ។ រាល់សំណើសុំទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតទាំងអស់ ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលសម្រេចបដិសេធចោល ដោយសារតែសំណើសុំទាមទារទាំងនោះនឹងមិនអាចបង្ខំឲ្យអនុវត្តបាន ឬ ដើម្បីអនុវត្តសំណើសុំទាមទារទាំងនោះបាន ពួកគាត់នឹងត្រូវការជាចាំបាច់នូវធនធានហិរញ្ញវត្ថុរបស់ កាំង ហ្គេកអ៊ាវ ដែលជាជនក្រីក្រ ឬតម្រូវឲ្យមានការបង្គាប់ទៅរដ្ឋកម្ពុជា។

សេចក្តីសង្ខេបនៃសាលដីកាលើបណ្តឹងសាទុក្ខ ដែលត្រូវបានប្រកាសនៅក្នុងសវនាការជាសាធារណៈ នាថ្ងៃនេះ មាននៅលើគេហទំព័រជាផ្លូវការរបស់តុលាការ (www.eccc.gov.kh)។ សាលដីកាលើបណ្តឹងសាទុក្ខទាំងមូលនឹងត្រូវបានផ្សព្វផ្សាយនៅពេលសមស្របខាងមុខ។